The following is an abridged translation of a sermon by John Piper. If you wish to read the original English, please go to the link below.

http://www.desiringgod.org/sermons/will-the-next-generation-know

# ស៊េរី៖ ការចិញ្ចឹមបីបាច់ថែរក្សា និងការបង្រៀនកូនៗឲ្យសង្ឃឹមលើជ័យជម្នះរបស់ព្រះជាម្ចាស់

# ពួកចៅហ្វាយ ២:៦-១៤

## បណ្ដាំជូនចំពោះលោកឪពុកអ្នកម្ដាយ

ថ្ងៃនេះ ខ្ញុំចង់ចែកចាយព្រះបន្ទូលព្រះជាម្ចាស់ឲ្យអ្នកទាំងអស់គ្នាអនុវត្តតាម ដើម្បីជាប្រយោជន៍ដល់ក្មេងៗនៅក្នុងក្រុមជំនុំរបស់យើង។ នៅក្នុងក្រុមជំនុំយើងមានអ្នកខ្លះមិនទាន់មានកូនចៅនឹងគេនៅឡើយទេ ហើយខ្លះក៏ប្រហែលជានឹងមិនមានផង។ ហើយអ្នកខ្លះទៀតក៏មានកូនធំពេញវ័យរួចទៅហើយដែរ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់ជំរាបដល់អ្នកទាំងអស់គ្នាឲ្យបានជ្រាប ពីព្រោះការដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់កូនៗរបស់យើងគឺជាការសំខាន់ខ្លាំងណាស់ ហើយក៏ជាផ្នែកមួយដែលទាក់ទងនឹងទស្សនវិស័យនៃជីវិតជាគ្រីស្ទបរិស័ទដែរ។ ក្នុងនាមជាអ្នកដែលមានវ័យចំណាស់ ការដែលត្រូវដឹងពីអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលមកកាន់កូនៗរបស់យើងនោះគឺជាការសំខាន់ណាស់។ យើងទាំងអស់គ្នាត្រូវមានចំណែកក្នុងការជួយថែរក្សា និងបង្ហាត់បង្រៀននូវសេចក្ដីដែលព្រះជាម្ចាស់បានបើកសម្ដែងដល់កូនៗជំនាន់ក្រោយ។ មិនថាខ្ញុំចែកចាយទៅកាន់កូនៗ ទៅកាន់លោកឪពុកអ្នកម្ដាយ ឬក៏អ្នកដែលនឹងធ្វើជាឪពុកម្ដាយគេនៅថ្ងៃខាងមុខនោះទេ គឺយើងទាំងអស់គ្នាចាំបាច់ត្រូវស្ដាប់ព្រះរាជសាររបស់ព្រះជាម្ចាស់ត្រង់នេះជាមួយគ្នាដោយយកចិត្តទុកដាក់។

## ជំណាកូនចៅដែលមិនស្គាល់ព្រះជាម្ចាស់

យោងតាមកណ្ឌគម្ពីរ ពួកចៅហ្វាយ ២:៨ យើងបានដឹងថា លោក យ៉ូស្វេ បានស្លាប់ទៅក្នុងជំនាន់អាយុ១១០ឆ្នាំ។ លោកបានដឹកនាំសាសន៍អ៊ីស្រាអែលឲ្យចូលទៅកាន់ទឹកដីកាណានដែលជាទឹកដីសន្យា ហើយបានទទួលជ័យជម្នះជាច្រើនលើកច្រើនសា ហើយក៏បានធ្វើជាគំរូនៃជំនឿលើព្រះជាម្ចាស់ដ៏ល្អម្នាក់ដែរ។ ក្រោយពីលោកបានស្លាប់ទៅ ក៏នៅមានអ្នកខ្លះដែលរស់នៅជំនាន់លោកនៅមានជីវិតរស់នៅនៅឡើយ ប៉ុន្តែមួយរយៈក្រោយមកពួកគេក៏បានស្លាប់ទៅដែរ។ ពេលដែលពួកគេនៅមានជីវិតនៅឡើយ ពេលនោះសាសន៍អ៊ីស្រាអែលបានបម្រើព្រះជាម្ចាស់យ៉ាងស្មោះត្រង់ ពីព្រោះពួកគេនៅចងចាំពីការដ៏អស្ចារ្យរបស់ទ្រង់នៅឡើយ។ កណ្ឌគម្ពីរ ពួកចៅហ្វាយ ២:៧ បានចែងថា «ពួកបណ្ដាជនក៏គោរពប្រតិបត្តិដល់ព្រះយេហូវ៉ា នៅគ្រប់១ជីវិតរបស់យ៉ូស្វេ និងពួកចាស់ទុំដែលរស់នៅក្រោយលោកដែរ *ជាពួកអ្នកដែលបានឃើញគ្រប់ទាំងការដ៏ធំ ដែលព្រះយេហូវ៉ាបានសម្រេចឲ្យពួកអ៊ីស្រាអែល*»។ ពេលដែលសាសន៍អ៊ីស្រាអែលនៅចងចាំពីការដ៏អស្ចារ្យដែលព្រះជាម្ចាស់បានសម្រេចសម្រាប់ពួកគេ ពួកគេក៏នៅតែបម្រើទ្រង់យ៉ាងស្មោះត្រង់ដដែល។

ប៉ុន្តែក្នុងខ១០បានចែងថា បន្ទាប់ពីលោក យ៉ូស្វេ និងពួកអ្នកដែលបានឃើញការអស្ចារ្យរបស់ព្រះជាម្ចាស់ ពួកគេបានស្លាប់អស់ទៅ ពេលនោះ «...មានមនុស្ស១ជំណាន់ទៀតក្រោយមក ជាមនុស្សដែលមិនបានស្គាល់ព្រះយេហូវ៉ា ឬការដែលទ្រង់បានសម្រេចដល់ពួកអ៊ីស្រាអែលទេ»។ ខ១១និង១២បានប្រាប់យើងពីលទ្ធផលនៃការមិនស្គាល់ព្រះជាម្ចាស់ «នោះពួកកូនចៅអ៊ីស្រាអែល ក៏ធ្វើការដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាវិញ គឺគេគោរពប្រតិបត្តិដល់អស់ទាំងរូបនៃព្រះបាល គេបានបោះបង់ចោលព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ដែលទ្រង់បាននាំគេចេញពីស្រុកអេស៊ីព្ទមក...»។ នៅក្នុងខ១៤បានពណ៌នាពីការដែលព្រះជាម្ចាស់ឆ្លើយតបទៅនឹងការដែលសាសន៍អ៊ីស្រាអែលក្រាបថ្វាយបង្គំព្រះដទៃយ៉ាងដូច្នេះថា «ដូច្នេះ ព្រះយេហូវ៉ាក៏កើតមានសេចក្តីខ្ញាល់នឹងពួកអ៊ីស្រាអែល ហើយទ្រង់ប្រគល់គេទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលបំផ្លាញគេ...»។

សរុបមក រឿងនេះមានលំដាប់លំដោយដូចតទៅ៖ ទីមួយ ពួកបណ្តាជនបានគោរពប្រតិបត្តិ ហើយបម្រើព្រះជាម្ចាស់ដែលជាព្រះដ៏ពិត ពីព្រោះលោក យ៉ូស្វេ និងពួកជំនាន់លោកបានរក្សានូវការចងចាំពីកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងចំណោមពួកគេ។ ទីពីរ មានមនុស្សមួយជំណាន់ទៀតបានកើតមក ជាមនុស្សដែលមិនបានស្គាល់ព្រះជាម្ចាស់ ឬការដែលទ្រង់បានសម្រេចដល់ពួកគេទេ។ ទីបី បណ្តាជនជំនាន់ថ្មីនេះបានបែរទៅតាមព្រះដទៃ ព្រមទាំងក្រាបថ្វាយបង្គំដល់ព្រះក្លែងក្លាយទៀតផង។ នៅទីបំផុត ព្រះជាម្ចាស់បានចាក់សេចក្តីខ្ញាល់របស់ទ្រង់លើពួកគេ។ មេរៀនបីដែលខ្ញុំដកស្រង់ពីអត្ថបទនេះយកមកចែកចាយវាមានលក្ខណៈសាមញ្ញ ប៉ុន្តែវាជាមេរៀនចាំបាច់ខ្លាំងណាស់។ មេរៀនទីមួយ នៅពេលដែលសហគមន៍ណាមួយរក្សាការចងចាំពីការអស្ចារ្យដែលព្រះជាម្ចាស់បានធ្វើ ជាពិសេសសហគមន៍ដែលធ្លាប់មានបទពិសោធន៍ទៅនឹងអំណាចរបស់ព្រះជាម្ចាស់ដោយផ្ទាល់ នោះជំនឿ ក៏ដូចជាការស្តាប់បង្គាប់របស់សហគមន៍នោះក៏នឹងកើនឡើងដែរ។ មេរៀនទីពីរ ប្រសិនបើយើងដែលជាឪពុកម្តាយមិនបានបង្រៀនកូនៗឲ្យស្គាល់ព្រះជាម្ចាស់ទេ នោះមានន័យថា យើងមិនត្រឹមតែនាំឲ្យពួកគេគ្មានជំនឿ និងបដិសេធទ្រង់ប៉ុណ្ណោះនោះទេ តែលើសពីនោះទៅទៀតយើងបាននាំឲ្យពួកគេហិនវិនាសទៀតផង។ មេរៀនទីបី កាតព្វកិច្ចឪពុកម្តាយគឺត្រូវតែបង្ហាត់បង្រៀនកូនចៅខ្លួនពីព្រះបន្ទូលព្រះជាម្ចាស់ ក៏ដូចជាការសង្គ្រោះរបស់ទ្រង់ ដើម្បីឲ្យកូនៗជំនាន់ក្រោយបានស្គាល់ទ្រង់ ហើយទទួលបានសេចក្តីសង្គ្រោះ។

ដោយសារតែមេរៀនពីរដំបូងបង្កើតបានជាមេរៀនទីបី ដូច្នេះខ្ញុំចង់និយាយពីមេរៀនទីបីនេះឲ្យបានក្បោះក្បាយបន្តិច។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះឪពុកម្តាយ គឺឲ្យពួកគាត់បង្ហាត់បង្រៀនកូនៗរបស់ខ្លួននូវអ្វីៗដែលទ្រង់បានបើកសម្តែងពីអង្គទ្រង់ឲ្យកូនៗបានស្គាល់។ ឯទំនួលខុសត្រូវដែលឪពុកម្តាយមានចំពោះកូនៗ គឺត្រូវបង្ហាត់បង្រៀនពួកគេឲ្យស្គាល់ពីចរិតលក្ខណៈរបស់ព្រះជាម្ចាស់ ក៏ដូចជាយល់ពីទ្រង់ឲ្យបានត្រឹមត្រូវ។ ផ្ទះគឺជាសាលារៀនដ៏សំខាន់បំផុតដែលកូនៗគួរទៅរៀន។ ឯគ្រូដ៏មានឥទ្ធិពលចំពោះកូនៗនោះគឺ ឪពុកម្តាយផ្ទាល់តែម្តង។

**ទីបន្ទាល់ពីព្រះគម្ពីរចំពោះលោកឪពុកអ្នកម្តាយ**

ជាដំបូង ខ្ញុំចង់ផ្តល់នូវភស្តុតាងមួយចំនួនចេញពីព្រះគម្ពីរដែលទាក់ទងនឹងការដាស់តឿនឪពុកម្តាយ បន្ទាប់មកខ្ញុំនឹងព្យាយាមឆ្លើយតបនឹងគំនិតជំទាស់លើការបង្រៀននេះ។ កណ្ឌគម្ពីរ ចោទិយកថា ៦:៤-៩ គឺជាខគម្ពីរយោងសម្រាប់ភស្តុតាងដ៏សំខាន់ចំពោះការបង្រៀននេះ។ បញ្ញត្តិដ៏សំខាន់បំផុតដែលដកស្រង់ចេញពីគម្ពីរសាសន៍យូដាគឺ «ចូរស្តាប់ចុះ ឱអ៊ីស្រាអែលអើយ ព្រះយេហូវ៉ាជាព្រះនៃយើង គឺព្រះយេហូវ៉ាតែ១អង្គទ្រង់ ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង»។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា នេះហើយជាបញ្ញត្តិដ៏សំខាន់បំផុត។ ដូចដែលសាសន៍យូដាគ្រប់គ្នាដឹង ហើយខ្ញុំក៏ចង់ឲ្យលោកអ្នកគ្រប់គ្នាដឹងដែរថាខគម្ពីរបន្ទាប់ពីបញ្ញត្តិដ៏សំខាន់នេះមានរៀបរាប់ពីអ្វីដែរ «សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ ត្រូវឲ្យប្រិតប្រៀនសេចក្តីទាំងនេះដល់កូនចៅឯង...»។ ទំនួលខុសត្រូវចម្បងរបស់ឪពុកម្តាយ គឺការស្រឡាញ់ព្រះជាម្ចាស់ បន្ទាប់ទៀតគឺការរក្សាព្រះបន្ទូលទ្រង់ក្នុងចិត្តពួកគេ ក៏ដូចជាការបង្ហាត់បង្រៀនព្រះបន្ទូលនោះដល់កូនៗពួកគេដែរ។

កណ្ឌគម្ពីរ ចោទិយកថា ៤:៩ ក៏បានបញ្ជាដូចខគម្ពីរខាងលើដែរ៖ «ប៉ុន្តែត្រូវឲ្យឯងរាល់គ្នាប្រយ័តខ្លួន ហើយរក្សាចិត្តឲ្យមែនទែន ក្រែងភ្លេចអស់ទាំងការ ដែលភ្នែកឯងបានឃើញ ហើយក្រែងនៅក្នុងជីវិតឯង ការទាំងនោះបានឃ្លាតចេញពីចិត្តឯងទៅ ត្រូវឲ្យឯងប្រាប់ពីការទាំងនោះដល់កូនចៅឯងឲ្យដឹងតរៀងទៅវិញ»។ ខគម្ពីរនេះក៏បាននិយាយសំដៅចំពោះជីដូនជីតា មិនគ្រាន់តែឪពុកម្តាយប៉ុណ្ណោះទេ។ កណ្ឌគម្ពីរ ចោទិយកថា ១១:១៨-១៩ ក៏ចែងស្រដៀងគ្នានឹង ៤:៩ ដែរ «ដូច្នេះ ត្រូវឲ្យរក្សាអស់ទាំងពាក្យអញទាំងនេះទុកនៅក្នុងចិត្ត ក្នុងព្រលឹងឯងចុះ...ត្រូវឲ្យបង្រៀនពាក្យទាំងនេះដល់ពួកកូនចៅឯង...»។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺឲ្យគ្រួសាររក្សានូវសេចក្តីដែលទ្រង់បានសម្តែងទុក។ ជាធម្មតា របៀបដែលកូនៗនៅជំនាន់ក្រោយអាចនឹងដឹងពីអ្វីដែលអ្នកជំនាន់មុនបានដឹង គឺតាមរយៈការបង្ហាត់បង្រៀនរបស់ឪពុកម្តាយ។ កណ្ឌគម្ពីរ យ៉ូអែល ១:៣ បានចែងថា «ចូរប្រាប់ដល់កូនអ្នករាល់គ្នាចុះ ហើយឲ្យកូនប្រាប់ដល់ចៅ រួចឲ្យចៅប្រាប់ដល់ដំណទៅមុខទៀតតៗទៅ»។

ព្រះគម្ពីរសញ្ញាថ្មីមិនសូវរៀបរាប់ពីឪពុកម្តាយ និងកូនៗប៉ុន្មានទេ។ ទោះជាយ៉ាងនេះក្តី ក៏យើងនៅតែឃើញយ៉ាងច្បាស់ថា ឪពុកម្តាយនៅតែមានទំនួលខុសត្រូវក្នុងការបង្ហាត់បង្រៀនកូនៗអំពីព្រះជាម្ចាស់ដែរ។ ក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១៩:១៤ យើងឃើញថា ព្រះយេស៊ូវបានបន្ទោសដល់ពួកសិស្សនៅពេលដែលពួកគេឃាត់មិនឲ្យកូនក្មេងមកឯទ្រង់។ ក្រោយមកទ្រង់ក៏បានទទួលពួកគេ ប្រទានពរដល់ពួកគេ ហើយទ្រង់ក៏បានសរសើរដល់ឪពុកម្តាយ ដោយសារពួកគេបានយកចិត្តទុកដាក់លើកូនៗខ្លួន។ មានមេរៀនដ៏ជាក់ច្បាស់មួយក្នុងអត្ថបទនេះគឺ៖ លោកឪពុកអ្នកម្តាយអើយ ចូរនាំកូនៗខ្លួនមកឯព្រះយេស៊ូវចុះ។ សព្វថ្ងៃនេះ របៀបដែលយើងចូលទៅឯព្រះយេស៊ូវគឺតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ហេតុដូច្នោះហើយ ឱលោកឪពុកអ្នកម្តាយរាល់គ្នាអើយ! ចូរបង្រៀនព្រះបន្ទូលដល់កូនៗខ្លួន ដើម្បីឲ្យពួកគេស្គាល់ព្រះយេស៊ូវផង។

នៅពេលដែលសាវ័ក ប៉ុល ណែនាំពីរបៀបដែលឪពុកម្តាយ និងកូនៗគួរមានទំនាក់ទំនងបែបណាក្នុងគ្រួសារជាគ្រីស្ទបរិស័ទចំពោះគ្នានឹងគ្នាក្នុងកណ្ឌគម្ពីរ អេភេសូរ ៦:១-៤ និងកូល៉ុស ៣:២០-២១ គាត់គ្រាន់តែបញ្ជាក់ជាថ្មីនូវលំនាំដែលព្រះគម្ពីរសញ្ញាចាស់បានបង្រៀនតែប៉ុណ្ណោះ៖ ឱកូនរាល់គ្នាអើយ! ចូរស្តាប់បង្គាប់ឪពុកម្តាយ! ឱឪពុករាល់គ្នាអើយ! ចូរបង្រៀនកូនៗទៅតាមដំបូន្មាន និងសេចក្តីដាស់តឿនរបស់ព្រះអម្ចាស់ចុះ!

យោងតាមបទគម្ពីរខាងលើនេះ ខ្ញុំសន្និដ្ឋានថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមានគ្រួសារ ហើយឲ្យឪពុកម្ដាយមានទំនួលខុសត្រូវក្នុងការបង្ហាត់បង្រៀនកូនៗឲ្យចេះដឹងអំពីព្រះគម្ពីរ។ ហេតុដែលកណ្ឌគម្ពីរ ពួកចៅហ្វាយ ២:១០ ចែងថា មានជំនាន់មនុស្សដែលមិនបានស្គាល់ព្រះជាម្ចាស់ ពីព្រោះមានឪពុកម្ដាយជាច្រើនមិនបានបំពេញទំនួលខុសត្រូវរបស់ខ្លួនដែលព្រះជាម្ចាស់បានប្រទានដល់ពួកគេទេ។ ជាលទ្ធផល មនុស្សជំនាន់ក្រោយៗទៀតបានបោះបង់ព្រះជាម្ចាស់ចោល ហើយបានបណ្ដាលឲ្យទ្រង់ជំនុំជម្រះពួកគេទៀតផង។ ខគម្ពីរទាំងនេះបានបង្ហាញយ៉ាងច្បាស់ថា ប្រសិនបើយើងដែលជាឪពុកម្ដាយមិនបំពេញទំនួលខុសត្រូវនេះទេ នោះយើងមិនគ្រាន់តែនាំឲ្យកូនៗយើងមិនស្គាល់ព្រះជាម្ចាស់ ហើយមិនឲ្យពួកគេជឿលើទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែយើងថែមទាំងនាំឲ្យពួកគេជួបនូវក្ដីហិនវិនាសផងដែរ។

**តើយើងកំពុងតែនាំឲ្យកូនៗយើងចេះរើសអើងឬ?**

ខ្ញុំចង់ឲ្យលោកឪពុកអ្នកម្ដាយនៅក្នុងក្រុមជំនុំយើងបង្ហាត់បង្រៀនកូនៗរបស់ខ្លួននៅផ្ទះ ដើម្បីឲ្យពួកគេស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ ឥឡូវ សូមអនុញ្ញាតឲ្យខ្ញុំឆ្លើយតបនូវជំទាស់ដែលលោកអ្នកអាចនឹងមាន។ ជំទាស់ទីមួយប្រហែលជាមានអ្នកខ្លះលើកឡើងថា ឪពុកម្ដាយគ្មានសិទ្ធិប្រាប់កូនៗពីសេចក្ដីពិតតាមចិត្តខ្លួនឯងនោះឡើយ។ គេថា ឪពុកម្ដាយគួរតែអនុញ្ញាតឲ្យកូនៗជ្រើសរើសសាសនាណាក៏បានដោយខ្លួនឯង ដើម្បីឲ្យការជ្រើសរើសរបស់ពួកគេកើតឡើងពីខ្លួនឯង មិនមែនដោយសារឪពុកម្ដាយជាអ្នកបង្ខិតបង្ខំនោះទេ។ ប៉ុន្តែ ការជំទាស់នេះមានបញ្ហាបួនយ៉ាង។ បញ្ហាទាំងនោះគឺ៖

១) គំនិតនោះ ផ្ទុយពីអ្វីដែលព្រះគម្ពីរបានបង្គាប់៖ ឪពុកម្ដាយត្រូវបង្រៀនកូនៗពីសេចក្ដីពិតអំពីព្រះជាម្ចាស់។

២) ទោះបើ យើងមិនបង្រៀនកូនៗរបស់យើងពីព្រះជាម្ចាស់ក៏ដោយ ក៏នោះមានន័យថាយើងកំពុងតែបង្រៀនគេអំពីព្រះជាម្ចាស់ ដោយសារយើងបង្រៀនគេថា ព្រះយេស៊ូវមិនសំខាន់អីបន្តិចសោះឡើយ។ ការដែលយើងមិនបង្រៀនពួកគេនោះក៏មានន័យថា ឪពុកម្ដាយមិនរាប់ទ្រង់ជាទីអំណរដូចគ្រឿងសង្ហារឹមថ្មីៗក្នុងផ្ទះ ឬថ្ងៃឈប់សម្រាក ឬការងារឪពុក ឬប្រធានបទក្នុងការសន្ទនារបស់ពួកគេនោះទេ។ ការមិនបង្រៀនពីគុណតម្លៃដ៏អស់កល្បជានិច្ចរបស់ព្រះគ្រីស្ទ គឺជាការបង្រៀនថាយើងមិនចាំបាច់អើពើនឹងទ្រង់ទេ។

៣) វាមិនមែនជាការពិតនោះទេដែលថា ការបង្រៀនកូនៗពីព្រះជាម្ចាស់នឹងនាំឲ្យពួកគេកប់គំនិត ឬក៏មានការរើសអើងដោយមិនចេះគិតគូរធ្វើការជ្រើសរើសដោយខ្លួនឯង។ ការនេះអាចកើតឡើងបាន ប្រសិនបើឪពុកម្ដាយស្ថិតក្នុងសភាពមិនរឹងមាំ ហើយជំនឿរបស់ពួកគាត់ដូចជាអ្នកសង់ផ្ទះលើដីខ្សាច់នោះ។ ប៉ុន្តែប្រសិនបើឪពុកម្ដាយមានមូលហេតុជាក់លាក់ក្នុងការធ្វើជាគ្រីស្ទបរិស័ទនោះពួកគេនឹងផ្ដល់មូលហេតុទាំងនោះទៅដល់កូនៗរបស់ពួកគេជាមិនខាន។ យើងឃើញស្រាប់ហើយថា មិនដែលមានអ្នកណាចោទឪពុកម្ដាយខ្លួនថា គាត់កំពុងតែនាំឲ្យកូនៗចេះរើសអើង ដោយសារតែពួកគេបង្រៀនកូនៗថា ផែនដីមានរាងមូល ផ្កាយតូចៗដែលយើងឃើញពេលយប់គឺធំជាងផែនដីទៅទៀត ហើយថាតាម

ពិតព្រះអាទិត្យនៅនឹងថ្កល់ហើយផែនដីវិលជុំវិញព្រះអាទិត្យនោះឡើយ។ ហេតុអ្វីបានជាគ្មានអ្នកចោទ? ពីព្រោះយើងដឹងហើយថា ការទាំងអស់នោះគឺជាការពិត ហើយយើងអាចផ្តល់ភស្តុតាងជាក់លាក់ ដើម្បីបង្ហាញកូនៗពីការពិតទាំងនេះ។ ការនេះមិនខុសពីជំនឿគ្រីស្ទបរិស័ទដែលជឿថា គ្រីស្ទសាសនាជាជំនឿពិត ដោយមានភស្តុតាងជាក់លាក់នោះទេ។

៤) ការមិនផ្តល់ឲ្យកូនៗនូវអ្វីដែលពួកគេពិតជាត្រូវការ នោះមិនមែនជាការស្រឡាញ់ដល់ពួកគេទេ ដោយសារយើងជឿថា កូនៗនឹងទទួលសេចក្តីសង្គ្រោះតាមរយៈជំនឿលើព្រះយេស៊ូវតែមួយប៉ុណ្ណោះ ហើយក៏អាចឲ្យពួកគេរួចផុតពីទុក្ខវេទនាក្នុងនរក បែរមកទទួលការអរសប្បាយនៅស្ថានសួគ៌វិញ ដូច្នេះយើងត្រូវបង្រៀនពួកគេពីផ្លូវដ៏ត្រឹមត្រូវ បើមិនដូច្នោះទេ មានន័យថា យើងមិនបានស្រឡាញ់ពួកគេសោះឡើយ។ ពេលខ្ញុំមើលកូនប្រុសជាទីស្រឡាញ់ទាំងបីនាក់របស់ខ្ញុំ ខ្ញុំតែងតែអធិស្ឋានថា «ឱព្រះគ្រីស្ទអើយ! កុំឲ្យទូលបង្គំបរាជ័យក្នុងការនាំកូនៗរបស់ទូលបង្គំទៅស្ថានសួគ៌ឡើយ»។

## ចុះបើខ្ញុំមិនសូវចេះព្រះគម្ពីរវិញ?

ជំទាស់ទីពីរដែលឪពុកម្តាយតែងតែជួបប្រទះគឺថា៖ ខ្ញុំមិនសូវចេះព្រះគម្ពីរទេ ដូច្នេះខ្ញុំក៏មិនអាចបង្រៀនកូនៗ ឬឆ្លើយសំណួរពិបាកៗរបស់ពួកគេបាននោះដែរ។ ខ្ញុំមានហេតុផលពីរយ៉ាងដែលខ្ញុំចង់លើកឡើង ដើម្បីកុំឲ្យលោកអ្នកគេចវេះក្នុងការបង្រៀនកូនៗ ដោយសារតែគិតថាខ្លួនឯងមិនសូវចេះព្រះគម្ពីរ។ ទីមួយ លោកអ្នកនៅតែអាចរៀនសូត្រ ហើយចម្រើនចំណេះដឹងអំពីសេចក្តីពិតនៃព្រះគម្ពីរបានគឺមិនទាន់ហួសពេលទេ។ លោកអ្នកប្រហែលនឹងក្លាយជាគ្រូបង្រៀនម្នាក់ដែលល្អជាងគ្រូបង្រៀនម្នាក់ទៀតដែលបានបង្រៀនព្រះគម្ពីរជាយូរមកហើយក៏ថាបាន ព្រោះព័ត៌មានអំពីព្រះគម្ពីរគឺថ្មីចំពោះលោកអ្នក។ និស្សិតមហាវិទ្យាល័យភាគច្រើនមិនដែលចាប់អារម្មណ៍ថា មុខវិជ្ជាដែលពួកគេកំពុងតែរៀនពីគ្រូ គឺជាមុខវិជ្ជាដែលគ្រូទើបតែបង្រៀនលើកដំបូងនោះទេ ហើយក៏មិនបានដឹងដែរថា គ្រូនោះចេះមិនលើសពួកគេប៉ុន្មាននោះដែរ។ ប៉ុន្តែជាទូទៅ គ្រូៗដឹងពីមេរៀនដែលគាត់នឹងត្រូវបង្រៀន ដូច្នេះគាត់អាចរៀបចំទុកជាមុន ហើយគាត់ក៏មានបទពិសោធន៍ខ្លះៗក្នុងការឆ្លើយសំណួរពិបាកៗដែរ។ ប្រសិនបើលោកអ្នកកំពុងតែស្ថិតនៅក្នុងកាលៈទេសៈដូចនឹងគ្រូបង្រៀននៅឯមហាវិទ្យាល័យ ទាក់ទងទៅនឹងការបង្រៀនកូនៗពីព្រះគម្ពីរ ចូរធ្វើដូចពួកគេចុះ ដោយរៀបចំមេរៀនឲ្យបានមុនមួយថ្ងៃ មុននឹងត្រូវបង្រៀន។ ឱ! ឪពុកម្តាយរាល់គ្នាអើយ កុំឲ្យភ្លេចឲ្យសោះឡើយថា ព្រះជាម្ចាស់បានប្រគល់ទំនួលខុសត្រូវក្នុងការបង្រៀនកូនៗដល់អ្នករាល់គ្នា ហើយក៏ត្រូវចាំដែរថា ទំនួលខុសត្រូវនោះ ធំជាងការដែលគ្រូមហាវិទ្យាល័យបង្រៀននិស្សិតទៅទៀត។

ទីពីរ លោកអ្នកមិនគួរអត់បង្រៀនកូនៗដោយសារតែលោកអ្នកមិនមានចំណេះដឹងអំពីព្រះគម្ពីរគ្រប់គ្រាន់នោះទេ ពីព្រោះលោកអ្នកនៅតែអាចបង្រៀនមេរៀនខ្លះៗបាន នៅពេលដែលលោកអ្នកមិនអាចឆ្លើយសំណួរពិបាកៗរបស់កូនៗ។ ឧទាហរណ៍ លោកអ្នកអាចបង្រៀនពួកគេឲ្យចេះបន្ទាបខ្លួន។ ប្រសិនបើលោកអ្នកមានមូលដ្ឋានមាំមួនក្នុងព្រះជាម្ចាស់ហើយ នោះលោកអ្នកនឹងហ៊ានបង្ហាញដល់កូនៗថា លោកអ្នកមិនចេះ ជាជាងអួតខ្លួន ឬក៏ធ្វើជាមនុស្សលាក់ពុតនោះឡើយ។ ពេលនោះកូនៗនឹងចេះបន្ទាបខ្លួនដែរ។ ឧទាហរណ៍មួយទៀត លោកអ្នកអាចបង្រៀនឲ្យកូនៗចេះបង្អើត

យុទ្ធសាស្ត្រខ្លះៗក្នុងការស្វែងរកចម្លើយលើសំណួរពិបាកៗដែលពួកគេមាន។ ឱ! ឪពុកម្ដាយរាល់គ្នាអើយ កុំបណ្ដោយឲ្យការមិនចេះព្រះគម្ពីររារាំងអ្នករាល់គ្នាមិនឲ្យបង្រៀនកូនៗនោះឡើយ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នករីកចម្រើនខាងឯវិញ្ញាណ ហើយទ្រង់ក៏នឹងជួយលោកអ្នកឲ្យធ្វើនូវអ្វីៗដែលត្រឹមត្រូវដែរ។

**ចុះបើកូនៗខ្ញុំមិនស្ដាប់បង្គាប់វិញ?**

ជំទាស់ចុងក្រោយដែលឪពុកម្ដាយតែងតែជួបប្រទះគឺថា កូនៗរបស់ខ្ញុំមិនចេះអង្គុយស្ងៀមយូរ ដើម្បីស្ដាប់ព្រះបន្ទូល ឬក៏ទទួលការប្រៀនប្រដៅឡើយ។ នេះជាបញ្ហាដ៏ធំមួយក្នុងព្រះវិហារសព្វថ្ងៃនេះ។ ប្រពន្ធខ្ញុំ និងខ្ញុំតែងតែឃើញបញ្ហានេះម្ដងហើយម្ដងទៀតនៅពេលដែលយើងទៅលេងកន្លែងផ្សេងៗ។ យើងឃើញឪពុកម្ដាយជាច្រើនមិនចេះមើលកូនៗគេសោះជាពិសេសនៅពេលដែលកូនៗមិនស្ដាប់បង្គាប់។ វាជារឿងដ៏គួរឲ្យចម្លែកណាស់ចំពោះយើង ពេលដែលយើងបានឃើញឪពុកម្ដាយដែលមានភាពវៃឆ្លាត មានការតាំងចិត្តយ៉ាងមុតមាំ ហើយមានសន្ដានចិត្តល្អស្មើរគ្រប់ជំពូក ប៉ុន្តែពួកគេបែរជាមិនចេះមើលកូនៗនៅពេលដែលកូនមិនស្ដាប់បង្គាប់។ មើលទៅវាហាក់ដូចជាឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទជាច្រើនជឿថា គេមិនអាចរំពឹងឲ្យកូនៗគេស្ដាប់បង្គាប់បានឡើយ។

ខ្ញុំជឿថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចំពោះស្ថានភាពត្រង់នេះចង់បង្រៀនថា ឪពុកម្ដាយត្រូវតែស្ដារនូវការរំពឹងឲ្យកូនៗស្ដាប់បង្គាប់ខ្លួនឡើងវិញ ហើយត្រូវស្ដារការដាក់វិន័យលើកូនៗឲ្យបានម៉ឺងម៉ាត់ តែត្រូវធ្វើដោយក្ដីស្រឡាញ់ និងការបន្ទាបខ្លួន ដែលការនេះអាចបណ្ដាលឲ្យកូនៗចេះស្ដាប់បង្គាប់។ បើមើលទៅ តាំងពីបុរាណមក ចរិតលក្ខណៈរបស់កូនៗមិនមានអ្វីខុសគ្នាពីកូនៗនៅពេលបច្ចុប្បន្ននេះឡើយ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងកណ្ឌគម្ពីរ សុភាសិត នៅតែពេញដោយប្រាជ្ញាដដែល។ កណ្ឌគម្ពីរ សុភាសិត ១៣:២៤ «អ្នកណាដែលមិនសូវប្រើរំពាត់ នោះឈ្មោះថាស្អប់កូន តែអ្នកណាដែលស្រឡាញ់កូនវិញ នោះឧស្សាហ៍វាយផ្ចាលវា»។ សុភាសិត ១៩:១៨ «ចូរវាយផ្ចាលកូន ក្នុងកាលដែលនៅមានសង្ឃឹមឲ្យវារាងចាលនៅឡើយ មិនគួរនឹងលើកលែងចោលវាឲ្យត្រូវវិនាសទេ...»។ សុភាសិត ២២:១៥ «សេចក្ដីចំកួតរមែងនៅជាប់ក្នុងចិត្តរបស់កូនក្មេង ប៉ុន្តែរំពាត់វាយផ្ចាល នឹងបណ្ដេញសេចក្ដីនោះ ឲ្យបាត់ចេញបាន»។ សុភាសិត ២៣:១៣-១៤ «កុំឲ្យខាននឹងវាយប្រដៅកូនឡើយ ដ្បិតបើវាយនឹងរំពាត់ គង់តែមិនស្លាប់ដែរ គឺឯងនឹងគ្រាន់តែវាយដោយរំពាត់ប៉ុណ្ណោះ ហើយយ៉ាងនោះ នឹងជួយព្រលឹងវាឲ្យរួចពីស្ថានឃុំព្រលឹងមនុស្សស្លាប់»។ សុភាសិត ២៩:១៥, ១៧ «រំពាត់ នឹងសេចក្ដីប្រៀនប្រដៅ រមែងឲ្យកើតមានប្រាជ្ញា តែកូនណាដែលបណ្ដោយឲ្យប្រព្រឹត្តតាមអំពើចិត្ត នោះតែងធ្វើឲ្យម្ដាយមានសេចក្ដីខ្មាសវិញ...ចូរស្ដីប្រដៅកូនឯងចុះ នោះវានឹងឲ្យឯងបានសំរាកចិត្ត អើ វានឹងឲ្យឯងមានចិត្តរីករាយផង»។

នៅពេលដែលកូនមានវ័យចម្រើនធំឡើងល្មម ដើម្បីអាចយល់ពីការបង្គាប់បញ្ជារបស់លោកអ្នក ហើយមានសមត្ថភាពគ្រប់គ្រាន់អាចធ្វើតាមបាន នោះលោកអ្នកដែលជាឪពុកម្ដាយគួរបង្រៀនកូនៗឲ្យចេះធ្វើអ្វីដែលត្រឹមត្រូវ ហើយក៏ត្រូវដាក់ពិន័យកូនៗនៅពេលដែលពួកគេមិនព្រមស្ដាប់បង្គាប់ រហូតទាល់តែពួកគេចេះស្ដាប់បង្គាប់មិនថានៅផ្ទះក្ដី ឬនៅមជ្ឈដ្ឋានខាងក្រៅក្ដី។ ប្រសិនបើខ្ញុំនិយាយសំដៅលើអ្នករំលោភបំពានសិទ្ធិកុមារ ខ្ញុំនឹងនិយាយច្រើនចំណុចបន្ថែមទៀត។ ការឱបថើប ការស្រឡាញ់ ការអត់ទោស និងការចំណាយពេលវេលាជាមួយកូនៗ វាសំខាន់ដូចជាការប្រៀនប្រដៅដែរ។ តាម

ធម្មតា ឪពុកម្តាយដែលមានវ័យចន្លោះពី២០-៣០ឆ្នាំមិនខ្វល់ចំពោះកូនៗក្នុងការមិនស្តាប់បង្គាប់ទេ តែដល់ពេលគេខ្វល់វិញ នោះវាហួសពេលបាត់ទៅហើយ ហើយពេលគេចង់ដាក់ពិន័យកូនៗនោះក៏ពុំសូវម៉ឺងម៉ាត់ និងទៀងទាត់ដែរ។ ចំពោះខ្ញុំ ខ្ញុំមិនមានជំនាញផ្នែកចិត្តសាស្រ្តអំពីចិត្តក្មេងៗនោះទេ។ ខ្ញុំគ្រាន់តែនិយាយចេញពីការយល់ដឹងរបស់ខ្ញុំទៅលើបទគម្ពីរ ពីបទពិសោធដែលខ្ញុំមានជាមួយកូនប្រុសទាំងបីរបស់ខ្ញុំ និងពីការសង្កេតមើលលើអ្នកដទៃតែប៉ុណ្ណោះ។

ខ្ញុំសុំបញ្ចប់មេរៀននេះជាមួយនឹងដំបូន្មានពីរ និងការសន្យាមួយ។ ដំបូន្មានទីមួយ សូមលោកឪពុកអ្នកម្តាយ ពិចារណាឲ្យបានម៉ត់ចត់ទៅលើកម្រិតនៃការបង្រៀនកូនៗពីព្រះជាម្ចាស់ និងការបង្រៀនឲ្យពួកគេស្តាប់បង្គាប់លោកអ្នកដែលជាតំណាងរបស់ទ្រង់ថាមានលក្ខណៈខ្លាំងក្លាប៉ុណ្ណា។ ដំបូន្មានទីពីរ ឪពុកម្តាយទាំងអស់មានទំនួលខុសត្រូវយ៉ាងចាំបាច់បំផុតក្នុងការបង្ហាត់បង្រៀនកូនៗខ្លួនអំពីព្រះជាម្ចាស់ និងអំពីក្តីសង្គ្រោះដ៏អស្ចារ្យរបស់ទ្រង់ដែរ (នេះហើយជាចំណុចចម្បងនៃមេរៀននេះ)។ ការបង្រៀនឲ្យពួកគេស្គាល់ពីការនេះគឺសំខាន់ណាស់ ព្រោះវាទាក់ទងនឹងការសង្គ្រោះរបស់ពួកគេ។ ដូច្នេះ ខ្ញុំសុំបញ្ចប់មេរៀនដោយលើកយកសេចក្តីសន្យាពីកណ្ឌគម្ពីរ សុភាសិត ២៣:២៤-២៥ «ឪពុកនៃមនុស្សសុចរិត នឹងមានចិត្តរីករាយយ៉ាងខ្លាំង ហើយអ្នកណាដែលបង្កើតកូនមានប្រាជ្ញា នោះនឹងមានសេចក្តីអំណរដោយសារកូននោះ ដូច្នេះ ចូរបើកឱកាសឲ្យឪពុកម្តាយឯងបានរីករាយចុះ ហើយឲ្យអ្នកដែលសំរាលឯងមកនោះមានចិត្តសប្បាយផង»។

សូមព្រះជាម្ចាស់បំពេញគ្រួសារយើងជាមួយនឹងអំណរបែបនេះឲ្យបានរៀងរហូតតទៅ!